# COVID-19 Vaccination Translation Project

Khmer |ភាសាខ្មែរ




@aacommission

# តើអ្នកដឹងឬទេ?

ការចាក់វ៉ាក់សាំងការពារ COVID-19 ត្រូវបានបង្ហាញថាមានប្រសិទ្ធភាពខ្ពស់ក្នុងការការពារជំងឺ ហើយវាជាឧបករណ៍សំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងរោគរាតត្បាតនេះ។ ការរួមបញ្ចូលគ្នានៃការចាក់វ៉ាក់សាំង ការពាក់របាំងមុខ និងការឃ្លាតឆ្ងាយពីគ្នា នឹងផ្តល់នូវការការពារដ៏ល្អបំផុតពីកូវីដ-19។ ព័ត៌មាននេះត្រូវបាននាំយកមកដោយ Mass.gov នាយកដ្ឋានសុខភាពសាធារណៈ។

នេះគឺជារោគសញ្ញាទូទៅមួយចំនួន ដែលមានលក្ខណៈធម្មតា៖ ឈឺដៃ ឡើងក្រហម ឡើងហើម អស់កម្លាំង ឈឺក្បាល ឈឺសាច់ដុំ ក្តៅខ្លួន ចង់ក្អួត រាងកាយត្រជាក់។
ប្រសិនបើអ្នកមានរោគសញ្ញាផ្សេងទៀត
ឬប្រសិនបើមានរោគសញ្ញាលើសជាងពីរ ឬបីថ្ងៃ សូមទូរស័ព្ទទៅអ្នកផ្តល់សេវាថែទាំរបស់អ្នក។

អ្នកអាចចាក់វ៉ាក់សាំងបាន ទោះបីអ្នកមិនមានប័ណ្ណធានារ៉ាប់រង អត្តសញ្ញាណប័ណ្ណ ប័ណ្ណបើកបរ ឬលេខ Social Security ក៏ដោយ។ ឯកសារទាំងនេះ មិនត្រូវការចាំបាច់នោះទេ។

ប្រសិនបើអ្នកត្រូវបានគេបដិសេធ មិនផ្តល់ការចាក់វ៉ាក់សាំង ឬមានបញ្ហាផ្សេងទៀត សូមទាក់ទងផ្នែក Attorney General Civil Rights Division **តាមលេខ** 617-963-2917 ឬដាក់ពាក្យបណ្តឹងតាមលើ បណ្តាញអ៊ីនធឺណិតនៅលើគេហទំព័រ https://www.mass.gov/how-to-file-a-civil-rights-complaint.

ប្រសិនបើមាននរណាម្នាក់ ស្នើសុំការប័ណ្ណធានារ៉ាប់រងរបស់អ្នក អត្តសញ្ញាណប័ណ្ណ ប័ណ្ណបើកបរ ឬលេខ Social Security អ្នកអាចនិយាយថាទេបាន។ អ្នកមិនចាំបាច់បង្ហាញឯកសារទាំងនេះ ដើម្បីទទួលបានការចាក់វ៉ាក់សាំងនៅក្នុងរដ្ឋម៉ាសាឈូសេត។

ការចាក់វ៉ាក់សាំងនឹងមិនប៉ះពាល់ដល់ស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។ រដ្ឋាភិបាលបានបញ្ជាក់ថានឹងមិនចាត់ទុកការព្យាបាលកូវីដ-19 (រួមទាំងការចាក់វ៉ាក់សាំង) ជាផ្នែកមួយនៃការកំណត់ស្ថានភាពអន្តោប្រវេសន៍របស់មនុស្សម្នាក់ឡើយ។

សំរាប់ការចាក់វ៉ាក់សាំងនេះដែរគឺឥតគិតថ្លៃសម្រាប់បុគ្គលទាំងអស់ ដែលរស់នៅ ធ្វើការ និងសិក្សានៅក្នុងរដ្ឋម៉ាស្សាឈូសេតដែលមានអាយុលើសពី 16 ឆ្នាំរួមទាំងជនអន្តោប្រវេសន៍គ្មានឯកសារឬគ្មានសិទ្ធិរស់នៅ។ វ៉ាក់សាំងនេះត្រូវបានផ្តល់ឱ្យដោយឥតគិតថ្លៃដល់បុគ្គលទាំងអស់ដោយរដ្ឋាភិបាល។
អ្នកមិនចាំបាច់ត្រូវការ ការធានារ៉ាប់រង
ដើម្បីទទួលថ្នាំវ៉ាក់សាំងឡើយ។ អ្នកនឹងមិនត្រូវបានស្នើសុំលេខកាតក្រេតឌីត ដើម្បីធ្វើការណាត់ជួបនោះទេ។

ប្រសិនបើអ្នកត្រូវបានគេបដិសេធ មិនផ្តល់ការចាក់វ៉ាក់សាំង ឬមានបញ្ហាផ្សេងទៀត សូមទាក់ទងផ្នែក Attorney General Civil Rights Division **តាមលេខ** 617-963-2917
ឬដាក់ពាក្យបណ្តឹងតាមលើ បណ្តាញអ៊ីនធឺណិតនៅលើគេហទំព័រ
https://www.mass.gov/how-to-file-a-civil-rights-com-plaint.

ប្រសិនបើអ្នកធ្លាប់មានកូវីដ -19 អ្នកក៏នៅត្រូវតែចាក់វ៉ាក់សាំងដដែល។ ប្រសិនបើអ្នកបានធ្វើតេស្តវិជ្ជមានសម្រាប់កូវីដ -19 អ្នកគួរតែរង់ចាំទទួលការចាក់វ៉ាក់សាំងរហូតដល់រយៈពេលដែលនៅដាច់ពីមនុស្សផ្សេងរបស់អ្នកបានចប់។ ជាធម្មតា ១០ ថ្ងៃក្រោយពីរោគសញ្ញាចាប់ផ្តើម ឬប្រសិនបើអ្នកមិនមានរោគសញ្ញាទេ ១០ ថ្ងៃក្រោយពីការធ្វើតេស្តរបស់អ្នកដែលចេញមកវិជ្ជមាន។

កំណត់ត្រាក្នុងការចាក់វ៉ាក់សាំងរបស់អ្នក នឹងត្រូវបានការពារពីការបើកបង្ហាញ។ នាយកដ្ឋានសុខភាពសាធារណៈ នឹងរក្សាកំណត់ត្រាអេឡិចត្រូនិករបស់អ្នកជំងឺម្នាក់ៗនៅរដ្ឋម៉ាសាឈូសេតដែលបានទទួលវ៉ាក់សាំងការពារកូវិដ-19 ។ មូលដ្ឋានទិន្នន័យការចាក់វ៉ាក់សាំងត្រូវបានរក្សាជាការសម្ងាត់ ដូចជាកំណត់ត្រាអ្នកជំងឺជាមួយគ្រូពេទ្យរបស់អ្នកជំងឺ។ ប្រសិនបើអ្នកជ្រើសរើសផ្តល់ឯកសារ (ប័ណ្ណធានារ៉ាប់រង អត្តសញ្ញាណប័ណ្ណ ប័ណ្ណបើកបរ ឬលេខ Social Security) ព័ត៌មានរបស់អ្នកនឹងត្រូវរក្សាទុកជាការសម្ងាត់។

**Go to www.aacommission.org > Resources > COVID-19 Resources**
for downloadable PDFs and graphics to share!

**These translations were undertaken by:**
*Springfield Vietnamese Cultural Association*
*Cambodian Mutual Assistance Association*
*Chinese Associations of Western MA*
*Bayanihan Association of America*
*Bhutanese Society of Western MA*
*Dr. Syed Irfan Makhdoom Nayyar,*
*Syeddah Ghazala, Syed Armughan*
*Dr. Zoubir Benmebarek*
*Farzana Junaise*

**Project direction by:**
*AAC's Health & Human Services Committee:*
*Commissioner Haniya Syeda and Commissioner Ekta Saksena*